# សេចក្តីថ្លែងការណ៍របស់លោកជំទាវតំណាងជាន់ខ្ពស់ Federica Mogherini ក្នុងនាម សហភាពអឺរ៉ុប ក្នុងឱកាសទិវាអន្តរជាតិប្រឆាំងការរើសអើងអ្នកស្រលាញ់ភេទដូចគ្នា អ្នកកែភេទ និងអ្នកស្រលាញ់ទាំងពីរភេទ

**ថ្ងៃទី ១៧ ខែ ឧសភា ឆ្នាំ ២០១៦**

នៅក្នុងឱកាសទិវាអន្តរជាតិប្រឆាំងការរើសអើងអ្នកស្រលាញ់ភេទដូចគ្នា អ្នកកែភេទ និងអ្នកស្រលាញ់ទាំងពីរភេទនេះ សហភាពអឺរ៉ុបសូមបញ្ជាក់ជាថ្មីអំពីការប្តេជ្ញាចិត្តដ៏រឹងមាំរបស់ខ្លួនចំពោះសមភាព និងសេចក្តីថ្លៃថ្នូររបស់មនុស្សជាតិទាំងអស់ដោយពុំគិតអំពីការបែងចែកបញ្ហាផ្លូវភេទ និង អត្តសញ្ញាណភេទឡើយ។

ទោះបីជាមានការរីកចម្រើនថ្មីៗនៅជុំវិញពិភពលោកក៏ដោយ ក៏នៅតែមានប្រទេសប្រមាណជិត ៨០ នៅតែមានការរើសអើងចំពោះទំនាក់ទំនងភេទដូចគ្នានៅឡើយ។ នៅទីកន្លែងជាច្រើន ការរើសអើង និងអំពើហិង្សាប្រឆាំងស្ត្រីដែលប្រតិព័ទ្ធស្ត្រីដូចគ្នា បុរសស្រលាញ់បុរស អ្នកស្រលាញ់ទាំងពីរភេទ អ្នកកែភេទ និងអ្នកប្តូរយេនឌ័រ (LGBTI) គឺកើតឡើងជារៀងរាល់ថ្ងៃ។ សហភាពអឺរ៉ុបសូមអំពាវនាវសារជាថ្មីដល់រដ្ឋាភិបាលទាំងអស់នៅជុំវិញពិភពលោកឲ្យគោរពគោលការណ៍សិទ្ធិមនុស្សអន្តរជាតិ បដិសេធន៍ការមិនអត់ឱន និងលើកកម្ពស់សមភាព ដូចមានចែងនៅក្នុងសេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស និងលិខិតូបករណ៍ផ្សេងៗទៀត។

នៅថ្ងៃនេះ សហភាពអឺរ៉ុបសូមលើកទឹកចិត្តចំពោះកិច្ចខិតខំប្រឹងប្រែងតស៊ូមតិដ៏មោះមុតរបស់ក្រុមអ្នកការពារ និងសកម្មជនសិទ្ធិមនុស្ស អ្នកសារព័ត៌មាន ព្រមទាំងអង្គការសង្គមស៊ីវិល ដើម្បីដោះស្រាយការរំលោភសិទ្ធិដែលក្រុម LGBTI កំពុងជួបប្រទះ។ ការងាររបស់អ្នកទាំងនោះពិតជាមានសារសំខាន់ខ្លាំងណាស់ក្នុងជំហានឆ្ពោះទៅរកការលើកយកបញ្ហានេះមកពិភាក្សា ការចងក្រងឯកសារអំពីការរំលោភបំពាន និងកិច្ចការពារសិទ្ធិមនុស្សជាមូលដ្ឋានប្រកបដោយប្រសិទ្ធភាព។

ដោយគោរពតាមគោការណ៍ណែនាំរបស់សហភាពអឺរ៉ុបស្តីពីសិទ្ធិរបស់ក្រុម LGBTI និងផែនការសកម្មភាពរបស់សហភាពអឺរ៉ុបស្តីពីសិទ្ធិមនុស្ស និងលទ្ធិប្រជាធិបតេយ្យ យើងនឹងបន្តធ្វើកិច្ចការជាមួយគ្រប់ដៃគូទាំងអស់ដើម្បីលើកកម្ពស់សិទ្ធិមនុស្សនៅជុំវិញពិភពលោក។